ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ..៨០១៩/១២/១៧../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី....២៨... ខែ...ធ្នូ..... ឆ្នាំ២០១២

**សូមជម្រាបជូន**
**អភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** ៖ សេចក្ដីណែនាំស្ដីពីចំណាយប្រតិបត្តិការ និងសកម្មភាពមួយចំនួន សម្រាប់ការរៀបចំ ផ.ស.ថ ២០១៣ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**<u>យោង</u>** ៖ ការវិភាជសម្រាប់ឆ្នាំ២០១៣ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្ដមមេត្តាជ្រាបថា ផ្អែកតាមស្ថានភាពធ្លាក់ចុះនៃការគាំទ្រមូលនិធិរបស់ដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១៣ តម្រូវឱ្យលេខាធិការដ្ឋាន គ.ជ.អ.ប បានដាក់ចេញនូវវិធានការក្នុងការកាត់បន្ថយនូវបុគ្គលិកមួយចំនួន ការបន្ថយប្រាក់បៀវត្ស ការតម្រឹមឡើងវិញនូវខ្ទង់ចំណាយមួយចំនួន ក៏ដូចជាវិធានការក្នុងការប្រើប្រាស់ និងការគ្រប់គ្រងចំណាយប្រតិបត្តិការនានា ដើម្បីធានាភាពសន្សំសំចៃ ការប្រើប្រាស់ចំទិសដៅ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ដែលរួមមានដូចខាងក្រោម ៖

**១. ការចំណាយប្រតិបត្តិការមួយចំនួន**

**១.១. ការចំណាយសម្រាប់ប្រេងឥន្ធនៈ និងការថែទាំម៉ូតូ**

- ការផ្ដល់របបប្រេង និងការថែទាំសម្រាប់ម៉ូតូ ត្រូវបានកាត់បន្ថយពី២៥ដុល្លារមក២០ដុល្លារក្នុងម្នាក់ក្នុងមួយខែ។
- ការផ្ដល់របបនេះ ត្រូវបានគណនាផ្អែកលើចំនួនមន្ត្រីផអព ចំនួនទីប្រឹក្សា និងចំនួនមន្ត្រីកិច្ចសន្យា (លើកលែងកមន្ត្រីគាំទ្រដូចជា អ្នកបើកបរ និងជំនួយការការិយាល័យ/ជំនួយការគណនេយ្យ) ដែលបំពេញការងារក្នុងរាជធានី ខេត្តនីមួយៗ។
- របបប្រេង និងការថែទាំចំនួន២០ដុល្លារនេះ គឺជាចំនួនមធ្យមសម្រាប់ការរៀបចំថវិកា ប៉ុន្តែការបែងចែកដល់បុគ្គលិកនីមួយៗ ត្រូវធ្វើឡើងតាមតម្រូវការជាក់ស្ដែងនៃការងាររបស់មន្ត្រីនីមួយៗដូចជាមន្ត្រីដែលបំពេញការងារភាគច្រើននៅមូលដ្ឋាន និងមន្ត្រីការិយាល័យជាដើម ។
- ការផ្ដល់របបប្រេង និងការថែទាំម៉ូតូ ត្រូវធ្វើឡើងក្នុងទម្រង់ជាប័ណ្ណប្រេង ពោលគឺមិនត្រូវបើកផ្ដល់ជាសាច់ប្រាក់ដល់បុគ្គលិកឡើយ ។
- **សម្រាប់មន្ត្រី ផអព** ៖ ការផ្ដល់របបប្រេង និងការថែទាំម៉ូតូត្រូវធ្វើឡើងប្រចាំខែ ផ្អែកតាមរបបដែលបានកំណត់ជាក់ស្ដែងរបស់រាជធានី ខេត្តនីមួយៗ ។


មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទៈ (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
Norodom Blvd., National Committee for Sub-National Democratic Development Secretariat (NCDDS). Ministry of Interior. Tel: (855-23) 720 061 / 720 038

- **សម្រាប់ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យា** ៖ ការផ្តល់របបប្រេង និងការថែទាំម៉ូតូ ត្រូវធ្វើឡើងនៅពេលមានបេសកកម្ម ឬតម្រូវការជាក់ស្តែង ពោលគឺមិនត្រូវផ្តល់ជារបបប្រចាំខែឡើយ ។

### ១.២. ការចំណាយសម្រាប់ប្រេងឥន្ធនៈរបស់រថយន្ត

- ការផ្តល់ប្រេងសម្រាប់រថយន្តរបស់រាជធានី ខេត្ត គឺចំនួន១៤០ដុល្លារសម្រាប់រថយន្តមួយគ្រឿងក្នុងមួយខែសម្រាប់ខេត្តដែលមានភូមិសាស្ត្រនៅជិតរាជធានីភ្នំពេញ និងងាយស្រួលធ្វើដំណើរ និងចំនួន២១០ដុល្លារសម្រាប់រថយន្តមួយគ្រឿងក្នុងមួយខែសម្រាប់ខេត្តដែលមានភូមិសាស្ត្រធំ និងពិបាកធ្វើដំណើរដូចជា ខេត្តកោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី ស្ទឹងត្រែង និងឧត្តរមានជ័យ ។
- រាជធានី ខេត្ត ត្រូវចាប់ផ្តើមរួមចំណែកជាបណ្តើរៗក្នុងការទទួលខុសត្រូវលើការចំណាយនេះ ។

### ១.៣. ការចំណាយសម្រាប់ប្រាក់បេសកកម្ម និងថ្លៃធ្វើដំណើរ

- ចំណាយប្រាក់បេសកកម្មសម្រាប់បុគ្គលិកនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងដោយផ្អែកលើចំនួនសរុបនៃមន្ត្រី ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាក្នុងរាជធានី ខេត្តនីមួយៗ ។ ចំណាយនេះត្រូវប្រើប្រាស់សម្រាប់មន្ត្រីថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលត្រូវចុះទៅបំពេញបេសកកម្មដើម្បីគាំទ្រក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងបេសកកម្មផ្សេងទៀត ។
- មន្ត្រីដែលចុះបំពេញការងារនៅមូលដ្ឋាននឹងទទួលបានរបបបេសកកម្ម ស្របតាមអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១២ មេសា ឆ្នាំ២០០៤ ស្តីពីការកំណត់របបបេសកកម្មក្នុង និងក្រៅប្រទេស ៖
  - ១៦ដុល្លារសម្រាប់បេសកកម្មស្នាក់នៅពេលយប់ ។ ខេត្តនីមួយៗ ត្រូវកំណត់ឱ្យបានច្បាស់អំពីទីតាំងភូមិសាស្ត្រដាច់ស្រយាលនានា ដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់នៅរៀងរាល់បេសកកម្ម ដើម្បីធានាការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ក្នុងទឹកដីរាជធានី ខេត្ត ការចំណាយក្នុងពេលត្រឡប់មកពីការបំពេញបេសកកម្មវិញ ពុំត្រូវបានអនុវត្តឡើយ ។
  - ៦ដុល្លារសម្រាប់បេសកកម្មមិនស្នាក់នៅពេលយប់ (មួយថ្ងៃ) ។ ភាគច្រើននៃបេសកកម្មរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវប្រើប្រាស់អត្រានេះ ។ ៣ដុល្លារសម្រាប់បេសកកម្មមិនស្នាក់នៅពេលយប់ (មួយថ្ងៃ) សម្រាប់ក្នុងទឹកដីរាជធានី ខេត្ត និងក្នុងរាជធានី ខេត្តដែលមានចម្ងាយផ្លូវតិចជាង១០គ.ម និងសម្រាប់ក្នុងទឹកដីខេត្តភូមិភាគឥសាន្តដែលមានចម្ងាយផ្លូវតិចជាង៥គ.ម លើកលែងតែបេសកកម្មនៅតាមមន្ទីរ អង្គភាពជុំវិញសាលារាជធានី សាលាខេត្ត សាលាស្រុក សាលាក្រុង សាលាខណ្ឌពុំទទួលបានរបបឧបត្ថម្ភនេះទេ ។
- ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យា នឹងមិនទទួលបានប្រាក់បេសកកម្មសម្រាប់ការចុះបំពេញការងាររបស់ខ្លួននៅមូលដ្ឋានឡើយ លើកលែងករណីបេសកកម្មស្នាក់នៅពេលយប់ ។
- មន្ត្រី ទីប្រឹក្សា និងមន្ត្រីកិច្ចសន្យាដែលទទួលបានរបបប្រេងឥន្ធនៈ និងការថែទាំសម្រាប់ម៉ូតូដូចមានបញ្ជាក់ក្នុងចំណុច១.១ខាងលើ នឹងពុំទទួលថ្លៃធ្វើដំណើរនៅពេលចុះបំពេញបេសកកម្មឡើយ ។

- ថ្លៃធ្វើដំណើរ គឺត្រូវទូទាត់តាមចំណាយជាក់ស្តែង។ រាជធានី ខេត្តនីមួយៗ ត្រូវរៀបចំតារាងថ្លៃធ្វើដំណើរជារូមមួយសម្រាប់ការប្រើប្រាស់ក្នុងរាជធានី ខេត្តទាំងមូល។
- ការទូទាត់ថ្លៃបេសកកម្មអាចអនុវត្តបានសម្រាប់បេសកកម្មណា ដែលមានការអនុញ្ញាតិពីប្រធានក្រុមការងារ ផអ៣ ឬអ្នកទទួលបានការផ្ទេរសិទ្ធិ និងត្រូវមានរបាយការណ៍ស្តីពីលទ្ធផលនៃបេសកកម្មនោះដែលបានពិនិត្យពីប្រធានក្រុមការងារ ផអ៣ ឬអ្នកទទួលបានការផ្ទេរសិទ្ធិ។

**២. ការវិភាជសម្រាប់ការអភិវឌ្ឍសមត្ថភាពជាក់លាក់**

- ការអភិវឌ្ឍសមត្ថភាពជាក់លាក់ គឺជាសកម្មភាពនៃការអភិវឌ្ឍសមត្ថភាព ផ្អែកតាមតម្រូវការរបស់ជាក់លាក់របស់រាជធានី ខេត្តនីមួយៗ ក្រៅពីការអភិវឌ្ឍសមត្ថភាពដែលនឹងត្រូវផ្តល់ដោយអនុកម្មវិធីនានា។ ចំណាយនេះត្រូវបានវិភាជផ្អែកតាមចំនួនក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តនីមួយៗ។

**៣. ការវិភាជសម្រាប់ គ.ក.ស.ក**

- មូលនិធិដែលបានវិភាជសម្រាប់គាំទ្រការបំពេញមុខងាររបស់ គ.ក.ស.ក រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់សម្រាប់ការចំណាយនានាដូចជាការរៀបចំកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក និងការចុះបេសកកម្មរបស់សមាជិក គ.ក.ស.ក នៅមូលដ្ឋាន។
- មូលនិធិវិភាជន៍នេះ មិនរួមបញ្ចូលការចំណាយសម្រាប់បេសកកម្ម និងថ្លៃធ្វើដំណើររបស់សមាជិក គ.ក.ស.ក ដែលមកពីក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក រាជធានី ខេត្ត និងសមាជិក គ.ក.ស.ក ដែលមកពីឃុំ សង្កាត់ ដើម្បីចូលរួមកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ ឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្នើឯកឧត្តមមេត្តាចាត់ចែង និងអនុវត្តតាមស្មារតីនៃលិខិតនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមជូនភ្ជាប់មកជាមួយនូវតារាងលម្អិតអំពីការវិភាជន៍សម្រាប់រាជធានី ខេត្ត។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**